Office of the Public Advocate

Khmer (Cambodian)

**Plan for the future: Decisions about your medical treatment**

# ផែនការសម្រាប់ពេលអនាគត



## ការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្ររបស់អ្នក

ប្រសិនបើអ្នកមិនអាចធ្វើការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រ ដោយសារតែអ្នកឈឺធ្ងន់ធ្ងរ ច្បាប់ចែងពីនរណាដែលអាចធ្វើការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នក។ ឧទាហរណ៍ ប្រហែលជាអ្នកសន្លប់ ឬមានការភាន់ច្រឡំខ្លាំងដោយសារតែជំងឺរបស់អ្នក។

ប្រសិនបើអ្នកមិនអាចធ្វើការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រ វេជ្ជបណ្ឌិតរបស់អ្នក នឹងសួរអ្នកទៅតាមលំដាប់អំពី៖

1. ប្ដី ប្រពន្ធ ឬដៃគូរបស់អ្នក
2. អ្នកថែទាំរបស់អ្នក (អ្នកដែលមើលថែរក្សាអ្នក) ប៉ុន្តែនេះមិនមែនជាបុគ្គលដែលបានទទួលប្រាក់ដើម្បីធ្វើការងារនេះទេ
3. កូនក្មេងពេញវ័យ (ចាស់ជាងគេ) របស់អ្នក
4. ឪពុកម្ដាយរបស់អ្នក
5. បងប្អូនប្រុស ឬស្រី (ចាស់ជាងគេ) របស់អ្នក។

អ្នកប្រហែលជាចង់ឱ្យមនុស្សម្នាក់ផ្សេងទៀតជាអ្នកធ្វើការសម្រេចចិត្ត អំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នក។

ឧទាហរណ៍ មិត្តភក្តិ ឬកូនពេញវ័យដែលក្មេងជាងគេរបស់អ្នក។



ដើម្បីជ្រើសរើសនរណាម្នាក់ផ្សេងទៀត អ្នកត្រូវ៖

- បំពេញសំណុំបែបបទពិសេសមួយ
- ធ្វើតាមការណែនាំនៅក្នុងសំណុំបែបបទនោះ អំពីរបៀបដែលអ្នកចុះហត្ថលេខាលើវា។

ប្រសិនបើអ្នកធ្វើតាមជំហានទាំងនេះត្រឹមត្រូវ អ្នកបានបង្កើតឯកសារស្របច្បាប់មួយ។

តើបុគ្គលនោះត្រូវធ្វើការសម្រេចចិត្តសម្រាប់អ្នកយ៉ាងដូចម្ដេច?

បុគ្គលដែលធ្វើការសម្រេចចិត្តសម្រាប់អ្នក ត្រូវធ្វើការសម្រេចចិត្តដែលពួកគេគិតថាអ្នកចង់បាន។ ដើម្បីជួយពួកគេ អ្នកគួរនិយាយជាមួយពួកគេ អំពីអ្វីដែលសំខាន់សម្រាប់អ្នក។

អ្នកក៏អាចបំពេញបែបបទមួយទៀតដែរ ដែលអ្នកអាចសរសេរចុះអំពីអ្វីដែលសំខាន់សម្រាប់អ្នកនៅក្នុងជីវិតរបស់អ្នក ហៅថា 'advance care directive'។

ក្នុងសំណុំបែបបទនេះ អ្នកក៏អាចធ្វើការសម្រេចចិត្តក្នុងពេលឥឡូវនេះ សម្រាប់ពេលអនាគតផងដែរ។ ឧទាហរណ៍ ប្រសិនបើអ្នកមានជំងឺធ្ងន់ធ្ងរ អ្នកប្រហែលជាដឹងរួចហើយពីការព្យាបាលផ្នែកវេជ្ជសាស្ត្រដែលអ្នកចង់បាន ឬមិនចង់បាននៅពេលអនាគត។

## តើមានអ្វីកើតឡើង ប្រសិនបើអ្នកមិនមានក្រុមគ្រួសារ?

ប្រសិនបើអ្នកមិនមានក្រុមគ្រួសារណាមួយទេ នោះ Public Advocate (អ្នកគាំទ្រសាធារណៈ) របស់រដ្ឋវិចថូរៀ អាចធ្វើការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នក ប្រសិនបើអ្នកមិនអាចធ្វើបានដោយខ្លួនឯងទេ។

Public Advocate (អ្នកគាំទ្រសាធារណៈ) នឹងព្យាយាមធ្វើការសម្រេចចិត្តតាមដែលអ្នកចង់បាន។

## កន្លែងដែលអាចរកបានទម្រង់បែបបទ

រកមើលសំណុំបែបបទដែលអ្នកត្រូវការ នៅក្នុងកូនសៀវភៅរបស់ Office of the Public Advocate (ការិយាល័យអ្នកគាំទ្រសាធារណៈ) (OPA) ហៅថា 'Take Control' និងនៅតាមវិបសៃថ៍របស់ OPA **www.publicadvocate.vic.gov.au**

សំណុំបែបបទនេះគឺឥតគិតថ្លៃទេ។

ដើម្បីជ្រើសរើសអ្នកដែលអាចធ្វើការសម្រេចចិត្ត អំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រសម្រាប់អ្នក ប្រសិនបើអ្នកមិនអាចធ្វើបានដោយខ្លួនឯងទេ អ្នកត្រូវបំពេញ៖

- សំណុំបែបបទ 'Appointment of medical treatment decision maker'។

ដើម្បីកត់ត្រាចុះពីអ្វីដែលមានសារៈសំខាន់សម្រាប់អ្នកនៅក្នុងជីវិតរបស់អ្នក ឬធ្វើការសម្រេចចិត្តអំពីការព្យាបាលផ្នែកវេជ្ជសាស្ត្រឥឡូវនេះសម្រាប់ពេលអនាគត អ្នកត្រូវបំពេញ៖

- សំណុំបែបបទ 'Advance care directive'។

ច្បាប់ចែងថាអ្នកអាចបំពេញសំណុំបែបបទទាំងនេះប៉ុណ្ណោះ ប្រសិនបើអ្នកយល់ដឹងច្បាស់ពីអ្វីដែលអ្នកកំពុងធ្វើ។

គ្មាននរណាម្នាក់បង្ខំអ្នកឱ្យធ្វើដូច្នេះទេ។

នេះគឺជាជម្រើសរបស់អ្នក។

## ប្រសិនបើអ្នកមានសំណួរណាមួយ

អ្នក ឬសាច់ញាតិ ឬមិត្តភក្តិរបស់អ្នកអាចទូរស័ព្ទទៅ OPA សម្រាប់ជំនួយ
លេខ 1300 309 337។

Interpreter

អ្នកអាចស្នើសុំអ្នកបកប្រែភាសាតាមទូរស័ព្ទ។